# សម្ភាសជាមួយឈ្មោះ កុត អឿន ភេទស្រី អាយុ៥២ឆ្នាំ

## មុខងារខ្មែរក្រហមៈ លើកទំនប់ត្រពាំងថ្ម

ស្រុកកំណើតនៅភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤២:១៥

ទំព័រ២១

ដានី ៖ អញ្ជឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងៗឈ្មោះអីដែរ?

អឿន ៖ ខ្ញុំឈ្មោះ អឿន ។

ដានី ៖ ឈ្មោះអីអឿន?

អឿន ៖ ឈ្មោះ កុត អឿន ។

ដានី ៖ មីងអាយុប៉ុន្មានហើយ?

អឿន ៖ ខ្ញុំអាយុ៥២ហើយ ។

ដានី ៖ ស្រុកកំណើតកើតជានៅណាដែរ?

អឿន ៖ នៅភូមិប៉ោយសំរោង ដែលខ្ញុំបានប្ដីហើយម៉ោនៅប៉ោយព្រីង ។

ដានី ៖ អ្ហូ!អញ្ជឹង?

អឿន ៖ ចា៎!

ដានី ៖ ស្រុកកំណើតនៅប៉ោយសំរោង?

អឿន ៖ ចា៎!សព្វថ្ងៃខ្ញុំនៅប៉ោយព្រីងទេ ។

ដានី ៖ ប៉ោយសំរោង ឃុំអីគេហ្នឹង?

អឿន ៖ ឃុំព្រះនេត្រព្រះហ្នឹង ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ បាទ!អញ្ជឹងសព្វថ្ងៃរសស់នៅភូមិ?

អឿន ៖ នៅភូមិប៉ោយព្រីង ឃុំព្រះនេត្រព្រះដែរ ។

ដានី ៖ ប្ដីរបស់មីងគាត់ឈ្មោះអីទៅអញ្ជឹង?

អឿង ៖ ឈ្មោះ គុណ ។

ដានី ៖ ឈ្មោះអីគុណត្រកូល?

អឿង ៖ សព្វថ្ងៃគេដាក់តែ ដម គុណៗ ។

ដានី ៖ ដម គុណ?

អឿង ៖ ដឹម គុណ តាគាត់ឈ្មោះ ដឹម ។

ដានី ៖ ឈ្មោះ ដឹម គុណ?

អឿង ៖ ចា៎!

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

អឿង ៖ អាយុ៥៣ហើយ ។

ដានី ៖ មីងមានកូនចៅប៉ុន្មាននាក់?

អឿង ៖ កូនខ្ញុំ១នាក់ ។

ដានី ៖ ស្រីឬប្រុស?

អឿង ៖ ប្រុស ។

ដានី ៖ មីងឪពុកមីងគាត់ឈ្មោះអីទៅ?

អឿង ៖ ឪពុកខ្ញុំឈ្មោះ ម៉ាង ។

ដានី ៖ ឈ្មោះ ម៉ាង គាត់នៅរស់ឬក៏?

អឿង ៖ នៅរស់ៗដល់សព្វថ្ងៃ ។

ដានី ៖ រស់នៅភូមិប៉ោយសំរោង?

អឿង ៖ ចា៎!ប៉ោយសំរោង ។

ដានី ៖ ចុះម្តាយ?

អឿង ៖ ម្តាយខ្ញុំឈ្មោះគាត់ ឈ្មោះយាយហ៊ីង ។

ដានី ៖ សព្វថ្ងៃគាត់នៅណាដែរ?

អឿង ៖ នៅប៉ោយសំរោងទាំងអស់គ្នាហ្នឹង ។

ដានី ៖ អញ្ចឹងបងប្អូនមានប៉ុន្មាន?

អឿង ៖ មាន៧នាក់ ។

ដានី ៖ ស្រី ប៉ុន្មានប្រុសប៉ុន្មាន?

អឿង ៖ ស្រី៤នាក់ ប្រុស៣នាក់ ។

ដានី ៖ ចុះមីងកូនទីប៉ុន្មានដែរ?

អឿង ៖ ខ្ញុំកូនច្បងគេទី១ ។

ដានី ៖ កូនទី១ ចុះកាលពីក្មេងៗបានរៀនសូត្រដល់ណាដែរ?

អឿង ៖ ខ្ញុំរៀនដល់ថ្នាក់ទីប៉ុន្មានទេ គេហៅថ្នាក់ទី១១ពីសង្គម ទី១១បើរាប់មកដល់សព្វថ្ងៃនេះ ថ្នាក់ទី១ តែរៀនមិនចេះទេ ខ្ញុំរវល់តែមើលប្អូនគ្មានបានរៀនប៉ុន្មានទេ ។

ដានី ៖ រវល់មើលប្អូន?

អឿង ៖ ចាំ!រវល់មើលតែប្អូនគ្មានសូវបានរៀនទេ រៀនតិចណាស់ មិនបានចេះគេទេ ។

ដានី ៖ បាទ!កាលហ្នឹងរៀននៅសាលាណា?

អឿង ៖ រៀនថ្នាក់ទី១១នៅរៀននៅព្រះនេត្រព្រះ ផ្សារចាស់ ថ្នាក់នៅសព្វថ្ងៃហ្នឹង ។

ដានី ៖ បាទ!ឈប់រៀនឆ្នាំណាមីង?

អឿង ៖ សម័យអាពតចប់យើងឈប់បណ្តោយ កាលសម័យចប់ហ្នឹងខ្ញុំទើបអាយុ១៤ ។

ដានី ៖ ប៉ុល ពតចូលក៏ឈប់បណ្តោយ?

អឿង ៖ ចាំ!១៤ក៏ឈប់បណ្តោយទៅ សម័យ៣ឆ្នាំបានអាយុ១៣-១៤-១៥-១៧-១៨ ។

ដានី ៖ ចុះពេលប៉ុល ពតចូលហើយឈប់រៀនធ្វើអីទៀតទៅ?

អឿង ៖ អាពតចូលមុនដំបូងគេឲ្យខ្ញុំទៅលើកទំនប់ បិទប្រឡាយ បោចស្មៅនៅវាលហាល គេឲ្យខ្ញុំទៅបោចស្មៅបានបន្តិច លើកទំនប់ ។

ដានី ៖ កាលហ្នឹងមីងនៅក្នុងកងអី?

អឿង ៖ នៅប្រធានកង ខ្ញុំនៅកន្លែងតម្បាញហ្នឹង គេឲ្យទៅត្បាញៗនៅវត្តព្រះនេត្រព្រះ ដល់ពេលវាមានកន្សែងមានអីត្បាញខ្ញុំ គេឲ្យខ្ញុំទៅដកស្មៅ ។

ដានី ៖ អញ្ចឹងដំបូងពេលដែលប៉ុល ពតចូលម៉ោហ្នឹង គេជ្រើសរើសមីងឲ្យទៅត្បាញ?

អឿង ៖ ចាំ!ត្បាញ ចុះណែ៎បងមិញគាត់ឆ្លើយថាត្បាញជុំគ្នានោះហើយ ដល់ពេលត្បាញទៅក៏អស់អំបោះឲ្យត្បាញគេឲ្យទៅលើកទំនប់បណ្តោយ ។

ដានី ៖ ត្បាញនៅវត្តណា?

អឿង ៖ នៅវត្តព្រះនេត្រព្រះហ្នឹងហើយ ។

ដានី ៖ អ៊ូ!ត្បាញអីទៅកាលហ្នឹង?

អឿង ៖ ត្បាញកន្សែងលោកគ្រូ ត្បាញក្រមា កន្សែង ។

ដានី ៖ បាទ!ត្បាញក្រមា កន្សែងនៅវត្តព្រះនេត្រព្រះ?

អឿង ៖ ចា៎!ក្បែរវត្តព្រះនេត្រព្រះ ផ្សារគេហ្នឹង ។

ដានី ៖ អ្នកណាគេអ្នកជ្រើសរើសឲ្យទៅត្បាញហ្នឹង?

អឿង ៖ នៅក្នុងស្រុកហ្នឹងឯង កាលសម័យអាពតខ្ញុំគេឲ្យខ្ញុំចល័តទៅនៅភូមិពោរចាត់ មិនមាននៅនេះទេ ភូមិពោរចាត់គេឲ្យរើសត្បាញ ខ្ញុំទៅនៅនោះក្មេង គេឲ្យរើសទៅនៅត្បាញ គេខ្ញុំក៏ទៅ ទៅជាមួយបងមិញហ្នឹងឯង ទៅជាមួយគ្នាហ្នឹង ដល់ពេលអស់កន្សែងត្បាញគេឲ្យទៅលើកទំនប់បណ្ដោយ បែកពីកន្សែងត្បាញគេឲ្យទៅលើកទំនប់ត្រពាំងថ្ម ។

ដានី ៖ អញ្ចឹងដល់ពេលគេឲ្យទៅត្បាញហ្នឹង ដល់ពេលអស់អំបោះ?

អឿង ៖ ចា៎!ខ្ញុំត្បាញបានមួយឆ្នាំណា៎លោកគ្រូ ។

ដានី ៖ បានមួយឆ្នាំអស់អំបោះអស់អីគេឲ្យទៅលើកទំនប់?

អឿង ៖ ចា៎!ទៅលើកទំនប់ ។

ដានី ៖ ពីណាអ្នកឲ្យទៅ?

អឿង ៖ អង្គការហ្នឹងឯងអ្នកឲ្យទៅ គេចាត់តាំងឲ្យពួកខ្ញុំទៅៗ ពួកខ្ញុំក៏ឲ្យទៅៗ ទៅបណ្ដោយ ទៅ ។

ដានី ៖ បាទ!កាលមីងត្បាញនៅវត្តព្រះនេត្រព្រះហ្នឹងមានគ្នាច្រើនទេ?

អឿង ៖ គ្នាមាន៣០នាក់លោកគ្រូ ។

ដានី ៖ អញ្ចឹងទៅត្បាញ៣០នាក់កាលហ្នឹងប្រធានគេឈ្មោះអីទៅ?

អឿង ៖ ប្រធានឈ្មោះយាយ អ៊ុត គាត់ស្លាប់បាត់អស់ហើយប្រធាន ។

ដានី ៖ អ៊ូ!ប្រធានឈ្មោះយាយអ៊ុត?

អឿង ៖ ចា៎!ប្រធានគេឈ្មោះយាយ អ៊ុត នៅប៉ោយសំរោងនោះ គាត់ស្លាប់អស់ហើយ គាត់ចាស់ហើយ ។

ដានី ៖ អញ្ចឹងកាលហ្នឹងត្បាញបានតែមួយឆ្នាំហើយ បានគេជ្រើសរើសឲ្យទៅ?

អឿង ៖ ចា៎!ទៅលើកទំនប់ លោកគ្រូខ្ញុំមិនមែនតែលើកទំនប់ទេ នោះខ្ញុំទៅបិទស្ទឹងនៅឱម៉ាល់កាត់នោះទៀត ហើយទៅបិទទំនប់នៅត្រពាំងថ្មនោះទៀតអ៊ូយ!ច្រើនណាស់ មួយថ្ងៃៗមិនដែលបានសម្រាកទេ ទៅបិទទំនប់នៅឱម៉ាល់ផ្លូវកាត់នោះចំនួន៣ខែ បិទទំនប់រួចគាស់គុលនោះទៀត ។

ដានី ៖ អញ្ចឹងដល់ពេលនេះអង្គការឲ្យទៅបិទទំនប់?

អឿង ៖ ចា៎!បិទទំនប់នៅឱម៉ាល់ផ្លូវកាត់នោះ នៅស្រុកកើតនោះ ។

ដានី ៖ ឱម៉ាល់នៅស្រុកណាទៅណា៎?

អឿង ៖ នៅកើតនោះ លោកគ្រូឯងកាលសម័យ៣ឆ្នាំនោះ ។

ដានី ៖ កើតហ្នឹងគេហៅភូមិអីគេ?

អឿង ៖ នៅភូមិទម្លាប់គេហៅនៅភូមិទម្លាប់ ។

ដានី ៖ ភូមិគោកទម្លាប់?

អឿង ៖ ចាំ!

ដានី ៖ កាលហ្នឹងបិទទំនប់?

អឿង ៖ បិទទំនប់ បិទស្ទឹង ។

ដានី ៖ បិទស្ទឹង?

អឿង ៖ ចាំ!រែកដី សែងដី ។

ដានី ៖ កាលហ្នឹងមីងចូលអីហើយកាលហ្នឹង?

អឿង ៖ កាលហ្នឹងខ្ញុំជាងកងអីទេ ប្រធានខ្ញុំមិត្តយ៉ន សមាជិកខ្ញុំឈ្មោះមិត្តឡេង តែគាត់២នាក់ហ្នឹងនៅស្រុកកើតនោះដែរ ។

ដានី ៖ ឈ្មោះមិត្ត យ៉ន?

អឿង ៖ ចាំ!បងយ៉នៗ ដល់អនុប្រធានមិត្តឡេង សមាជិកនោះមិត្តណាំង ។

ដានី ៖ បាទ!ចុះមីងធ្វើជាអី?

អឿង ៖ ខ្ញុំកូនក្រុមគេ ។

ដានី ៖ កូនក្រុម?

អឿង ៖ ចាំ!មិនបានធ្វើប្រធានអីទេ ខ្ញុំកូនក្រុមគេ ។

ដានី ៖ កាលហ្នឹង កាលនៅក្នុងកងហ្នឹងសុទ្ធតែយើងនៅអាយុប្រហែលៗគ្នា ឬក៏យើងចាស់ៗហើយ?

អឿង ៖ ចាំ!គាត់បងខ្ញុំគាត់អាយុច្រើនជាងខ្ញុំគាត់អាយុ២២-២៣ ខ្ញុំអាយុ១៧ ។

ដានី ៖ ក្រោពីបិទទំនប់រួចគេឲ្យធ្វើអីទៀត?

អឿង ៖ បិទទំនប់រួចគេឲ្យគាស់គល់ៗកាប់ស្រែ ។

ដានី ៖ គាស់គុលនៅណា កាប់ស្រែនៅណា?

អឿង ៖ នៅនោះឯង កាប់នៅឱម៉ាល់ផ្លូវកាត់នោះ កាប់ស្រែៗឲ្យគេធ្វើ កាប់ស្រែទៅគាស់ គុល ។

ដានី ៖ កាប់ស្រែគាស់គុលហ្នឹងរយៈពេលប៉ុន្មានទៅ?

អឿង ៖ កាប់ស្រែកាស់គុលហ្នឹងចំនួន៣ខែបានរួចលោកគ្រូ ។

ដានី ៖ កាលហ្នឹងយើងយ៉ាងម៉េចដែរ កាលនៅត្បាញក្រមារ កាស់គុល កាប់ស្រែអីហ្នឹងកាល ហ្នឹងយើងហូបចុកអីយ៉ាងម៉េច ហើយយើងបានមកលេងផ្ទះលេងអីឬអត់?

អឿង ៖ មិនដែលបានម៉ោឃើញផ្ទះទេ ខ្ញុំមិនដែលហានសុំគេម៉ោទេ ខ្ញុំខ្លាចគេណាស់ ខ្ញុំនៅដល់ ចប់៣ឆ្នាំបានម៉ោផ្ទះ ។

ដានី ៖ អ្ហូ!អត់ដែលម៉ោលេងសោះ?

អឿង ៖ ចា៎!មិនដែលម៉ោលេងទេ តាំងពីម៉ែខ្ញុំមានប្អូនកូនង៉ា ឥឡូវកូនធំហើយខ្ញុំមិនស្គាល់ផង មកដល់អត់ស្គាល់ប្អូនទេ មិនដែលបានម៉ោផ្ទះទេ ខ្ញុំខ្លាចគេណាស់ មិនដែលបាននៅ ឈឺក៏យកទៅពេទ្យ ម៉ោពីពេទ្យវិញក៏ម៉ោកន្លែងធ្វើការវិញ ។

ដានី ៖ ចុះហូបចុកអីម៉េចដែរ?

អឿង ៖ លោកគ្រូបាយគេវាល់ល្បប ម្នាក់ម៉ាចានៗ ម៉ាចានត្រាមាន់ ។

ដានី ៖ ហើយហូបឆ្អែតទេ?

អឿង ៖ ទេ!មិនឆ្អែតទេលោកគ្រូចេះតែរំដឹកទឹកឲ្យច្រើនៗទៅ ដាក់អំបិលឲ្យប្រៃៗទៅ វាស្រេក ទឹកទៅក៏ដឹកទឹកទៅឲ្យឆាប់ឆ្អែត ។

ដានី ៖ អញ្ចឹងពេលនៅកកន្លែងឱម៉ាល់ហ្នឹង៣ខែហើយ មីងទៅណាទៀត?

អឿង ៖ ចល័តម៉ោដើមគរ៣ដើមលោកគ្រូ ។

ដានី ៖ ផ្លាស់ម៉ោកន្លែងដើមគរ៣ដើម?

អឿង ៖ ចា៎!ម៉ោដើមគរ៣ដើមដកស្ទូង ធ្វើស្រែ ។

ដានី ៖ នៅកន្លែងដើមគរ៣ដើម នៅកន្លែងហ្នឹងដកស្ទូងធ្វើស្រែ?

អឿង ៖ ចា៎!

ដានី ៖ កាលហ្នឹងមីងនៅក្នុងកងអីគេទៅ?

អឿង ៖ កងប្រធានខ្ញុំឈ្មោះនេះឯង ប្រធានកងចល័តសហជីប គេឲ្យទៅម្តងទៅនេះទៅនោះ គេចង់ស្រេចតែដកយើងទៅ ។

ដានី ៖ កងចល័តគ្នាច្រើនទេកាលហ្នឹង?

អឿង ៖ គ្នាច្រើនណាស់ ១០០នាក់ទៅ២០០នាក់ហ្នឹងឯងគ្នាច្រើនណាស់ ។

ដានី ៖ កាលហ្នឹងកងចល័តរបស់ភូមិ ឬរបស់អីគេ?

អឿន ៖ ចល័តរបស់ភូមិភាគគេហ្នឹង គេដកទៅនេះក៏ទៅៗ គេដកទៅនោះក៏ទៅៗ ស្រេចតែគេបញ្ជាហ្នឹងចេះតែទៅតាមគេ ។

ដានី ៖ តំបន់អីក៏ភូមិភាគអីយ៉ាងម៉េច អីក៏ស្រុក?

អឿន ៖ ភូមិហ្នឹងឯង ខ្ញុំចល័តទៅនៅភូមិ គេដក ចល័តភូមិៗភាគស្រេចតែគេដក គេដកទៅណាស្រេចតែគេ ^មិនសូវស្គាល់អីដងកាលពីដើម ខ្ញុំនៅតំបន់៥គ្រាន់តែគេដកទៅណាក៏ទៅតាមគេទៅ ។

ដានី ៖ ចុះមីងកាលដកស្ទូងនៅគរពាដើមបានយូរទេ?

អឿន ៖ យូរដល់ហើយលោកគ្រូ នៅឡើងទាល់តែចប់សម័យ៣ឆ្នាំ ចប់សម័យអាពត ។

ដានី ៖ ចុះមីងអត់បានទៅត្រពាំងថ្មទេ?

អឿន ៖ ទៅៗនៅហ្នឹងដែរ ទៅរួចត្រឡប់ពីហ្នឹងហើយបានម៉ោនេះវិញ ។

ដានី ៖ អ្ហូ!អញ្ចឹងទៅកន្លែងគរពាដើមបានរយៈពេលប៉ុន្មានបានទៅ?

អឿន ៖ ត្រឡប់ទៅលើកទំនប់រួចបានម៉ោវិញនៅគរពាដើមនេះចប់បណ្តោយ ចប់ក៏ម៉ោផ្ទះ ។

ដានី ៖ អញ្ចឹងដំបូងមីងចេញពីឪម៉ាល់ ពីគោកទម្លាប់ហ្នឹងក៏ទៅគរពាដើម?

អឿន ៖ ចា៎!ទៅគរពាដើម ដល់ពេលគេដកពីគរពាដើម ។

ដានី ៖ គរពាដើមហ្នឹងទៅនៅធ្វើស្រែរយៈពេលប៉ុន្មានទៅ?

អឿន ៖ ដកស្ទូងធ្វើស្រែ មើលខ្ញុំទៅហ្នឹងទល់តែចប់សម័យ៣ឆ្នាំ ដល់ពេលខ្ញុំទៅលើកទំនប់នោះលើកទំនប់នោះរួចគេដកម៉ោនេះវិញ ។

ដានី ៖ បាទ!ប៉ុន្តែពូថា កាលហ្នឹងមីងទៅគរពាដើមហើយបានគេបញ្ជូនមីងឲ្យទៅត្រពាំងថ្មអី?

អឿន ៖ ចា៎!បញ្ជូនឲ្យទៅនោះទៀត ។

ដានី ៖ បាទ!អញ្ចឹងកាលហ្នឹងមីងទៅហ្នឹងបានរយៈពេលប៉ុន្មាន បានបញ្ជូនម៉ោកន្លែងត្រពាំងថ្ម?

អឿន ៖ អ្ហូ!ដូចទៅយូរដែរ ដូចប៉ុន្មានខែដែរដូចមិនសូវចាំទេខ្ញុំ៣ខែ-៤ខែមិនដឹងលើកទំនប់ ។

ដានី ៖ ៣ខែ-៤ខែ?

អឿន ៖ ចា៎!

ដានី ៖ ៣ខែ-៤ខែហើយបានគេបញ្ជូនមីងឲ្យម៉ោលើកទំនប់នៅត្រពាំងថ្ម?

អឿន ៖ ចា៎!

ដានី ៖ កាលម៉ោត្រពាំងថ្មហ្នឹង កាលហ្នឹងនៅកន្លែងណាទៅ?

អឿន ៖ ពីដើមនៅគោកចេក ហើយដល់គេដកពីនោះទៅ ទៅនៅនោះរួច ដល់ពេលលើកអាទំនប់ហ្នឹងរួចដកម៉ោគោកចេកវិញ ។

ដានី ៖ ប៉ុន្តែកាលទៅត្រពាំងថ្មហ្នឹងនៅម្តុំណាទៅត្រពាំងថ្ម?

អឿន ៖ មិនដឹងត្រង់ណាត្រង់ណីទេខ្ញុំមិនសូវចាំទេ គ្នាច្រើនពេកៗអញ្ចឹងខ្ញុំមិនសូវចាំទេ គេធ្វើខុមឲ្យវែងអញ្ចឹងទៅគេក៏ដាក់តាមកងៗ ៣០នាក់ៗអញ្ចឹងទៅ ។

ដានី ៖ បាទ!តាមកង៣០នាក់ៗ?

អឿន ៖ ចាំ!តាមកង៣០នាក់ៗ គេធ្វើរោងឡើងវែងអញ្ចឹងទៅ នៅម៉ាកងៗ ប្រធានកងខ្ញុំ ឈ្មោះមិត្តបឿន មិត្តឡេង មិត្តយ៉ន ។

ដានី ៖ អញ្ចឹងកាលហ្នឹងមីងនៅកន្លែងត្រពាំងថ្មហ្នឹងអត់ដឹងម្តុំណាទេ?

អឿន ៖ មិនដឹងណាទេ នៅវែងគេខុមអញ្ចឹងទៅក៏គេឲ្យនៅក៏នៅទៅ នៅអែបទំនប់ហ្នឹង ។

ដានី ៖ បាទ!ចុះគេឲ្យលើកអីមួយថ្ងៃប៉ុន្មានដែរ?

អឿន ៖ ឲ្យលើកដូចតែគ្នាហ្នឹង ដូចតែបងនិយាយមុនអញ្ចឹងមួយថ្ងៃ៣ម៉ែត្រគីប បើយើងមិនរួចទៅគេបន្ថត់បាយយើង ចេះតែខំទៅណាំ!សែងទៅ រែកដង ជញ្ជូនដង បើយើងមិនរួចទៅគេមិនឲ្យបាយហូប ។

ដានី ៖ អញ្ចឹងកាលហ្នឹងគេឲ្យយើងលើក៣ម៉ែត្រគីប?

អឿន ៖ ចាំ!៣ម៉ែត្រ ៤ម៉ែត្រ ។

ដានី ៖ ដូចព្រឹកឡើងគេវាស់ឲ្យយើងលើក ឬក៏យ៉ាងមេចឬក៏យើង?

អឿន ៖ ចាំ!ព្រឹកឡើងគេវាស់ឲ្យរៀងខ្លួនម្នាក់៣ម៉ែត្រ ម្នាក់៤ម៉ែត្រទៅ យើងលើកថ្ងៃនេះរួច ៣ម៉ែត្រ ស្អែកឡើងយើងលើក៤ តែបើយើងលើកមិនរួចក៏យើងធ្វើឲ្យតែរួច មិនរួចក៏គេមិនឲ្យហូបបាយទេ ពេលរួចថែមទៅវិញ បើយើងលើកកាន់តែរួចកាន់តែថែម ។

ដានី ៖ អញ្ចឹងកាលមីងទៅត្រពាំងថ្មដីបូងកាលហ្នឹង មានដាទំនប់ហើយឬមិនទាន់មានទេ?

អឿន ៖ មិនទាន់មានទេ ទឹមវាស់លើកដូចបងគាត់ថាមិញត្រឡប់បណ្តោយគ្នា គេកន្លែងចាក់ត្រង់នេះ ខ្ញុំកន្លែងចាក់ទៅ រែកទៅចាក់ចូលគ្នាទៅណាំ ។

ដានី ៖ ចុះគេមានបោះអីចំណាំឬក៏ទៅឃើញវាលស្រែសុទ្ធហ្នងកាលហ្នឹង?

អឿន ៖ ចាំ!វាលស្រែសុទ្ធ ទៅៗក៏គេវាស់ទៅ ចេះតែលើករែកទៅ គេក៏ចាក់ត្រង់នេះទៅ ខ្ញុំក៏ចាក់ត្រង់នេះទៅចូលគ្នា ។

ដានី ៖ ចុះកន្លែងដែលយើងកាប់ដី កន្លែងយើងកាប់ដីវាស់ដីថាឲ្យយើងវែកហ្នឹងថាពីហ្នឹងម៉ោ ទំនប់ហ្នឹង ឆ្ងាយទេ?

អឿង ៖ ជិតហ្នឹងលោកគ្រូ ជិតដូចថាប្រហែលពីត្រឹមហ្នឹងទៅរទេះនោះ ចំងាយ៤-១០ម៉ែត្រ ចំងាយប្រហែល១០ម៉ែត្រ ។

ដានី ៖ ចំងាយប្រហែល១០ម៉ែត្រ?

អឿង ៖ ចាំ!

ដានី ៖ យើងចាក់ទាល់តែខ្ពស់ហ្នង?

អឿង ៖ ចាំៗ!ចាក់ទាល់តែខ្ពស់ហ្នឹងហើយ ។

ដានី ៖ កាលហ្នឹងកម្ពស់ប៉ុន្មានទៅមីងមានដឹងទេ?

អឿង ៖ មិនដឹងប៉ុន្មានម៉ែត្រទេលោកគ្រូ ខ្ញុំមិនបានដាចាំផង ខ្ញុំវារាងតែឈឺស្អមផងមិនសូវចាំទេ ខ្ញុំមិនសូវមានកម្លាំង ចេះតែវែកទាំងជំទិតទាំងជំទូងទៅ យ៉ាប់ណាស់ ខ្ញុំឈឺឡើងស្អម ។

ដានី ៖ ចុះមីងកាលហ្នឹងបើព្រលឹមឡើងគេវាស់ឲ្យយើង៣ម៉ែត្រអញ្ចឹង ដល់ម៉ោងប៉ុន្មានទៅ បានយើងវែកហើយ?

អឿង ៖ អើយ!លោកគ្រូឡើងដល់ម៉ោង៥ ពេលណាក៏ម៉ោង៤ ពេលណាក៏ម៉ោង៣ទៅស្រេច តែយើងថ្ងៃណាមានកម្លាំងទៅក៏បានលឿនបន្តិចទៅ ថ្ងៃណារាងខ្សោយក៏ដល់ម៉ោង៥ បានរួច ។

ដានី ៖ ចុះគេមានដែលហៅយើងទៅប្រជុំប្អូអត់?

អឿង ៖ មិនដែលអត់ទេ មួយខែគេទៅប្រជុំមួយដង បើកសន្និបាតម្តងទៅ ជួនណាកន្លះខែ មួយដងទៅគេប្រជុំឲ្យយើងប្រឹងប្រែងលើកទំនប់ ឲ្យយើងប្តេជ្ញាធ្វើម៉េចឲ្យបានតែឆាប់ រួច ។

ដានី ៖ បាទ!ប្រជុំហ្នឹងប្រជុំទាំងអស់គ្នាប្អូក៏ប្រជុំ?

អឿង ៖ ទាំងអស់គ្នា ។

ដានី ៖ ទាំងអស់គ្នា បើតាមមីងប៉ាន់ស្មានមើលប្រហែលជាប៉ុន្មានទៅ?

អឿង ៖ អ៊ូ!លោកគ្រូអើយច្រើនណាស់មនុស្សរាប់ពាន់នាក់នោះ ស្គាល់គ្នាមិនអស់ទេ មិនដឹងជា អ្នកណាខ្លះអ្នកណីខ្លះទេ ខ្ញុំមិនស្គាល់មើលទៅក៏ដាច់កន្ទុយភ្នែកចេះ លើកហែរវែងចេះ ទៅគេក៏លើក យើងក៏លើក ប្រធានកងគេរៀងៗខ្លួនខ្ញុំក៏មិនស្គាល់គេអស់ទេ គេក៏ មិនស្គាល់ខ្ញុំដែរ ។

ដានី ៖ បាទ!ពេលគេប្រជុំហ្នឹងគេប្រជុំនៅកន្លែងណាទៅ?

អឿន ៖ ជិតហ្នឹងឯង ជិតកន្លែងលើកទំនប់ហ្នឹង ។

ដានី ៖ ជិតកន្លែងលើកទំនប់ គេហៅម៉ុំអីគេប្រជុំហ្នឹង?

អឿន ៖ មិនដឹងគេហៅម៉ុំអីគេ ខ្ញុំក៏មិនសូវស្គាល់ដែរ នៅនេះដល់ពេលលើកនោះ មិនសូវស្គាល់ថាត្រង់ណាត្រង់ណីទេ ប្រជុំក្បែរតែកន្លែងលើកទំនប់ហ្នឹង គេហៅប្រជុំគ្នាទាំងអស់ ។

ដានី ៖ បាទ!ពីណាគេអ្នកដែលម៉ោបើកអង្គប្រជុំហ្នឹង?

អឿន ៖ ពួកតាម៉ោង តាវ៉ាល់ហ្នឹងឯង គេហៅតាម៉ោង តាវ៉ាល់ៗ ។

ដានី ៖ តាម៉ោង តាវ៉ាល់ហ្នឹងគាត់ម៉ោប្រជុំ?

អឿន ៖ ចា៎!គាត់ម៉ោប្រជុំម្តងៗ ។

ដានី ៖ ហើយគាត់និយាយថាម៉េចពេលប្រជុំ?

អឿន ៖ ប្រជុំគាត់ថាឲ្យតែយើងប្តេជ្ញាហ្នឹងហើយ ប្តេជ្ញាលើកទំនប់លើកប្រឡាយ ឲ្យយើងខំបងប្អូនខំប្រឹងប្រែង កូនចៅខំប្រឹងប្រែងលើកទំនប់ លើកប្រឡាយឲ្យឆាប់រួច ។

ដានី ៖ ប្តេជ្ញាលើកទំនប់ លើកប្រឡាយឲ្យឆាប់រួច?

អឿន ៖ ចា៎!ឲ្យយើងខំ បងប្អូនខំព្រឹងប្រែង កូនចៅខំប្រឹងប្រែងឲ្យឆាប់រួច ។

ដានី ៖ ចុះគាត់មានប្រាប់ថា គេលើកទំនប់ហ្នឹងដើម្បីធ្វើអីដែរ?

អឿន ៖ ទេ!ខ្ញុំក៏មិនបានឮ គេឲ្យលើកចេះតែលើកៗទៅណា៎! មិនដឹងជាគេឲ្យធ្វើអីៗមិនបានប្រាប់ទេ ។

ដានី ៖ អត់ដឹងថាគេឲ្យលើកទំនប់ហ្នឹងដើម្បីធ្វើអីៗទេ?

អឿន ៖ អត់ដឹងផង ។

ដានី ៖ ពេលប្រជុំគាត់អត់មាននិយាយទេ តាម៉ោង តាវ៉ាល់អីហ្នឹង?

អឿន ៖ អត់ទេ!អត់មិនបាននិយាយអីទេ និយាយតែឲ្យយើងប្តេជ្ញាខំលើករៀងៗខ្លួន ឲ្យយើងលើកប្តេជ្ញាថាខំលើកទំនប់ ខំជីកប្រឡាយ ប្តេជ្ញាតែគេប្រធានៗលោកគ្រូ ។

ដានី ៖ បាទ!កាលហ្នឹងមីងអត់ដឹងទេ អត់ដឹងថាគេលើកដើម្បីធ្វើអីទេ?

អឿន ៖ ខ្ញុំមិនដឹងធ្វើអីទេលោកគ្រូអើយ! ខ្ញុំវានៅក្មេងដែរ ។

ដានី ៖ ចុះពីខាងអ្នកធំៗអីគេមានដែលម៉ោមើលអីប៉ុអត់?

អឿន ៖ គេម៉ោមើលលោកគ្រូ គេម៉ោប្រជុំម៉ោអីដូចថាបើកមហាសន្និបាតអីគេម៉ោ ។

ដានី ៖ បាទ!ចុះក្រៅពីតាវ៉ាល់ តាម៉ោងហ្នឹងមានអ្នកផ្សេងទៀតទេ?

អឿង ៖ មាន!មានគេអ្នកសៗមកយាយ ភាសាព្រៃព្រុសខ្ញុំមិនសូវស្គាល់ទេ ព្យែតគេនិយាយភាសាគេ មានអ្នកបកប្រែមានអ្នកអីៗ

ដានី ៖ អ្ហ៊ូ!សៗ និយាយភាសាអីទៅ?

អឿង ៖ មិនដឹងគេនិយាយភាសាអីទេ ខ្ញុំក៏មិនហានទៅជិតគេ ខ្ញុំខ្លាចគេនោះ ខ្ញុំនៅឆ្ងាយៗ

ដានី ៖ ប៉ុន្តែមិនមែននិយាយភាសាខ្មែរទេ?

អឿង ៖ មិនមែននិយាយភាសាខ្មែរទេ ព្យែតថាចិនៗ សៗធាត់ៗៗ

ដានី ៖ គេម៉ោនិយាយថាម៉េច?

អឿង ៖ គេនិយាយតែគ្នាគេហ្នឹងលោកគ្រូ ខ្ញុំមិនចេះស្ដាប់បានអីៗ

ដានី ៖ គេម៉ោហ្នឹងគេធ្វើការនៅទំនប់ហ្នឹងដែរឬ?

អឿង ៖ គេម៉ោមើលម្ដងៗ បើកឡានម៉ោ កូនឡានតូចៗ

ដានី ៖ គ្នាប៉ុន្មាននាក់ម៉ោម្ដងៗ?

អឿង ៖ បើមិន៣នាក់ ៤នាក់ហ្នឹងឯងៗ

ដានី ៖ ៣នាក់-៤នាក់គេជិះឡានអីម៉ោ?

អឿង ៖ ហ៊ូ!មិនស្គាល់ឡានគេទេ មិនដឹងឡានស្អីទេ អាឡានសៗតូចៗហ្នឹងៗ

ដានី ៖ ឡានសៗតូចៗ មីងអត់ដឹងថាគេហៅម៉ាក់ឡានហ្នឹងម៉ាកឡានស្អីទេ?

អឿង ៖ អ្ហ៊ូ!មិនស្គាល់ទេ ពីសង្គមខ្ញុំមិនដែលឃើញឡានផង ទឹមឃើញពីសម័យសព្វថ្ងៃនេះលោកគ្រូៗ

ដានី ៖ អញ្ចឹងមានចិនមានអីគេម៉ោវាស់វែងអញ្ចឹងដែរ?

អឿង ៖ គេមិនបានម៉ោវាស់ទេ វាស់ៗតែប្រធានក្រុមទេ លោកគ្រូៗ

ដានី ៖ វាស់តែប្រធានក្រុម ប៉ុន្តែគេម៉ោមើល?

អឿង ៖ គេគ្រាន់តែម៉ោមើលទំនប់មើលអី យើងលើកហើយអីហើយៗ

ដានី ៖ អ្ហ៊ូ!ប៉ុន្តែគេខស្សប្រាហ៍ម៉ោដែរ?

អឿង ៖ ទេ!យូរៗគេម៉ោម្ដង ឃើញម៉ោ៣ដងៗ

ដានី ៖ ពេលឃើញពួកសៗ ពួកចិនៗម៉ោហ្នឹងឃើញតាវ៉ាល់ តាម៉ោងអីគាត់ម៉ោជាមួយដែរឬអត់?

អឿង ៖ ម៉ោលោកគ្រូ ម៉ោដើរជាមួយគ្នាៗ

ដានី ៖ អញ្ចឹងប្រជុំៗម្ដងៗរយៈពេលប៉ុន្មានទៅ?

អឿង ៖ ២ម៉ោង-៣ម៉ោងហ្នឹង ។

ដានី ៖ ២ម៉ោង-៣ម៉ោងហ្នឹងគេនិយាយអីខ្លះ បើថានិយាយតែប្តេជ្ញាលើកទំនប់ ហើយនិយាយអីទៀត បើនិយាយតែប៉ុនហ្នឹង?

អឿង ៖ ចា៎!និយាយតែប្តេជ្ញាហ្នឹង ប្រធានក្រុមគេនិយាយតែប្តេជ្ញា គេនិយាយតែគ្នាគេ ខ្ញុំមិនចេះស្តាប់បាន ។

ដានី ៖ អ៊ូ!គេអត់មានទិទានយើងថា អ្នកណាលើកបានតិច ហើយគេសរសើរអ្នកណាលើកបានច្រើនអី គេមាននិយាយនៅក្នុងអង្គប្រជុំទេ?

អឿង ៖ សរសើរដែរ អនុប្រធានណាលើកបានច្រើនអញ្ចឹងគេឲ្យយើងកម្លាំងទី១ គេលើកបានលឿនទៅគេដាប់ឈ្មោះកម្លាំងទី១ អ្នកលើកបានតិចទៅកម្លាំងទី២ កម្លាំងទី៣ ប៉ុនមិនសូវអ្នកណាលើកបានតិចទេ សុទ្ធតែប្តេជ្ញាគ្រប់គ្នា លើករួចដូចតែគ្នា លើកមិនរួចទេជួយគ្នា ជួយនៅក្នុងក្រុមយើងគេឲ្យជួយឲ្យរួចទាំងអស់គ្នា បើយើងមិនរួចទេគេមិនឲ្យយើងឡើងម៉ោហូបបាយទេ ។

ដានី ៖ មីងដែលឃើញមុខតាវ៉ាល់ទេ?

អឿង ៖ និយាយមិនស្គាល់ម៉េច តែឥឡូវភ្លេចមុខអស់ហើយ ។

ដានី ៖ បាទ!កាលហ្នឹងស្គាល់ដែលហ៊ាននិយាយជាមួយគាត់ដែរ?

អឿង ៖ ទេ!ខ្ញុំមិនដែលហ៊ាននិយាយទេ ខ្លាចគេលោកធំៗ ។

ដានី ៖ គាត់កាច?

អឿង ៖ គាត់កាចគ្រាន់ដែរ សម្លុតបាត់ៗមាត់ ។

ដានី ៖ គាត់កាចជាងអ្នកធំឥឡូវទៀត?

អឿង ៖ កាចៗណាស់ កាចជាងអ្នកធំសព្វថ្ងៃ ។

ដានី ៖ អ្នកធំឥឡូវគេអត់កាចទេ?

អឿង ៖ ទេ!អត់កាចទេ ។

ដានី ៖ គេអត់ខ្លាចដូចពីមុនទេ?

អឿង ៖ ខ្លាចដែរបើយើងធ្វើខុស បើយើងមិនបានធ្វើខុសទេ មិនដឹងខ្លាចធ្វើអី ។

ដានី ៖ តែពីមុនខ្លាចរហូត?

អឿង ៖ ខ្លាចណាស់លោកគ្រូអើយ តែឃើញគេម៉ោវិញញ័រដៃញ័រជើង ខ្លាចណាស់ ។

ដានី ៖ ឃើញគេញ័រដៃញ័រជើង ម៉េចបានកាលនោះខ្លាចម្ល៉េះ?

អឿង ៖ ខ្លាចគេយកទៅវៃចោល មិនខ្លាចម៉េចបើគេយកទៅវៃចោលទាំងខ្សែៗ ។

ដានី ៖ អញ្ចឹងមីងធ្លាប់ធ្វើឃើញគេបណ្ដើរទៅវៃចោលដែរ?

អឿង ៖ ឃើញ គ្រាន់តែមិនដឹងថាគេយកទៅណាម៉ោណីទេ ខ្ញុំឃើញគេខ្ញុំខ្លាចញ័រខ្លួនទទ្រើក ។

ដានី ៖ ចុះមីងពេលប្រជុំម្ដងៗតាវ៉ាល់ តាម៉ោងអីគេអត់មានប្រាប់យើងគេលើកទំនប់ហ្នឹង ដើម្បីទប់ទឹក ឬក៏ស្តុកទឹកសម្រាប់ធ្វើអីៗគេអត់មានប្រាប់ណា?

អឿង ៖ ទេបើឮថាទប់ទឹកខ្ញុំមិនដែលឮគេថាទេ ប៉ុនតាមគេថាទុធ្វើស្រែប្រាំង ។

ដានី ៖ គេឲ្យធ្វើស្រែប្រាំង?

អឿង ៖ ចាំ!

ដានី ៖ ស្រែប្រាំងនៅណា?

អឿង ៖ ប៉ុនមិនទាន់បានធ្វើផងក៏ចប់សម័យ៣ឆ្នាំ ។

ដានី ៖ កាលនោះពីណាអ្នកថាគេទប់ទឹកដើម្បីធ្វើស្រែប្រាំង?

អឿង ៖ តាម៉ោង តាវ៉ាល់ហ្នឹងគាត់អ្នកឲ្យធ្វើស្រែប្រាំងៗ ។

ដានី ៖ ធ្វើស្រែប្រាំងនៅម្ដុំណា?

អឿង ៖ ម្ដុំជិតនោះឯង វាលជិតភ្នំស្រុក ត្រពាំងថ្មហ្នឹង ។

ដានី ៖ តែមិនទាន់បានធ្វើទេ?

អឿង ៖ មិនទាន់បានធ្វើទេក៏ចប់ ។

ដានី ៖ កលាហ្នឹងតាវ៉ាល់ តាម៉ោងគាត់ថាទប់ទឹកធ្វើស្រែប្រាំងគាត់និយាយពេលប្រជុំឬនិយាយណា?

អឿង ៖ និយាយពេលប្រជុំ ។

ដានី ៖ ម៉ាខែ ឬកន្លះខែ?

អឿង ៖ បើជួនណាក៏ម៉ាខែ ជួនណាក៏កន្លះខែមិនទៀងទេ ។

ដានី ៖ ពេលប្រជុំច្រើនប្រជុំពេលណា?

អឿង ៖ ប្រជុំយូរៗមួយខែគេហៅប្រជុំម្ដង ។

ដានី ៖ បាទ!ខ្ញុំដឹងតែគេប្រជុំពេលថ្ងៃ ឬពេលយប់?

អឿង ៖ ពេលព្រឹកៗ ពេលម៉ោង៨យើងជួបជុំគ្នា ដល់ម៉ោង១១ក៏ចប់ទៅ ។

ដានី ៖ អញ្ចឹងប្រជុំអញ្ចឹងមួយថ្ងៃហ្នឹងអត់ធ្វើការទេ?

អឿង ៖ ថ្ងៃប្រជុំគេអត់ឲ្យធ្វើការទេ គេឲ្យសម្រាក ។

ដានី ៖ បាទ!ដល់ពេលប្រជុំចប់ក៏អត់ធ្វើការដែរ?

អឿន ៖ អត់ទេ!គេឲ្យសម្រាកមួយថ្ងៃ ។

ដានី ៖ អ្ហូ!គេឲ្យសម្រាកមួយថ្ងៃ អញ្ចឹងយើងចូលចិត្តប្រជុំឬអត់បើគេឲ្យសម្រាកអញ្ចឹង?

អឿន ៖ ទេ!បើគេឲ្យប្រជុំក៏សុខចិត្តប្រជុំទៅ បើយូរៗម្តងម៉ាខែ ។

ដានី ៖ អញ្ចឹងយូរៗមួយដងអញ្ចឹង ពេលប្រជុំហើយ ថ្ងៃហ្នឹងគេឲ្យសម្រាកហើយ អត់ឲ្យធ្វើការទេ?

អឿន ៖ ចា៎!

ដានី ៖ មីងធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង បើប្រៀបធៀបយើងធ្វើការនៅកន្លែងទំនប់ផ្សេងៗ យើងធ្វើការយ៉ាប់ដូចគ្នាឬក៏យ៉ាងម៉េច?

អឿន ៖ អ្ហូ!យ៉ាប់ណាស់លោកគ្រូអើយ ឡើងស្គមអស់នៅសល់តែស្បែកដណ្តប់ឆ្អឹង ។

ដានី ៖ បាទ!កាលមីងនៅកន្លែងត្បាញនៅវត្ត ហើយនៅបិទទំនប់នៅឱម៉ាល់ នៅដើមគរ៣ដើមអី?

អឿន ៖ បើខ្ញុំទៅនៅកន្លែងត្បាញខ្ញុំធាត់ កាលហ្នឹងខ្ញុំអត់ស្គមទេ ខ្ញុំធាត់ ។

ដានី ៖ ស្គមនៅណា?

អឿន ៖ ស្គមនៅកន្លែងលើកទំនប់ត្រពាំងថ្មនេះឯង សែនដីមួយថ្ងៃ២-៣ម៉ែត្រគីប ។

ដានី ៖ អ្ហូ!កាលនៅគរ៣ដើមនោះអត់អីទេ?

អឿន ៖ ចា៎!កាលនោះម៉ាគ្រាន់ ដូចថាយើងមធ្យម ។

ដានី ៖ អ្ហូ!ទៅកន្លែងត្រពាំងហ្នឹងស្គមហ្មង?

អឿន ៖ ចា៎!ដល់ចប់សម័យហ្នឹងមកកន្លែងដើមគរ៣ដើមកាន់តែស្គមទៅៗ ម៉ែខ្ញុំម៉ោគាត់មើលខ្ញុំមិនស្គាល់ទេ គាត់ឃើញខ្ញុំគាត់គេចខ្ញុំ ។

ដានី ៖ គាត់មើលអត់ស្គាល់?

អឿន ៖ ចា៎!គាត់មិនដឹងថាកូនឯង ។

ដានី ៖ ធ្វើរាល់តែថ្ងៃហ្មង?

អឿន ៖ ចា៎!គ្មានថ្ងៃអាទិត្យទេលោកគ្រូ ។

ដានី ៖ ចុះហូបចុកអីមីងហូបបានឆ្អែតដែរ?

អឿន ៖ មិនបានឆ្អែតទេលោកគ្រូ បានតែម៉ាកូនចានគ្រាមាន់ ។

ដានី ៖ ដល់អត់ឆ្អែតគេមានអីបន្ថែមទៀតទេ?

អឿង ៖ គ្មានអីបន្ថែមទៀតទេ អត់មានអីទេខ្ញុំមិនដឹងរកអីបានបន្ថែមទេ មិនចេះដូចអ្នកថ្មីដើរ ចេះដ៏ចេះអី ។

ដានី ៖ ចុះមីងធ្វើការជាមួយអ្នកថ្មីដែរ?

អឿង ៖ ធ្វើជុំគ្នាហ្នឹងហើយ ។

ដានី ៖ ហើយពួកអ្នកថ្មីម៉េចដែរពួកអ្នកថ្មី?

អឿង ៖ គ្នាស្គមដល់ហើយ ធំតែក្បាលជង្គង់ ស្គមជាងកូនខ្ញុំទៀត ។

ដានី ៖ អញ្ចឹងពួកគាត់ធ្វើការស៊ូដែរឬអត់ស៊ូទេ?

អឿង ៖ ស៊ូ!ស៊ូដូចតែគ្នាហ្នឹង ចេះតែទៅទាំងងាប់ទាំងរស់ហ្នឹង បើមិនស៊ូណាខ្លាចគេយកទៅវៃចោល ចេះតែខំប្រឹងធ្វើទៅ ។

ដានី ៖ ដល់ហូបអត់ឆ្អែតអញ្ចឹងទៅចេះបន្ថែហូបបន្ថែមទៅ?

អឿង ៖ គ្មានបន្លែណាចេះ ។

ដានី ៖ អត់មានឈើព្រៃមានអី?

អឿង ៖ អត់មានទេ កណ្ដាលវាលស្រែសុទ្ធ ។

ដានី ៖ គេឲ្យហូបប៉ុណ្ណា ហូបប៉ុណ្ណឹង?

អឿង ៖ ចា៎!គេឲ្យហូបប៉ុណ្ណា ហូបប៉ុណ្ណឹងដូចខ្ញុំនិយាយប្រាប់លោកគ្រូអញ្ចឹងថា ផឹកទឹកឲ្យច្រើន ។

ដានី ៖ ផឹកទឹកឲ្យច្រើន សំបូរទឹកផឹកអីម៉េច?

អឿង ៖ អត់ទេ!ទឹកវាមានគ្រាន់តែម៉ាផឹកៗ ។

ដានី ៖ មានទឹកម៉ាផឹកៗ?

អឿង ៖ ចា៎!

ដានី ៖ ចុះទឹកល្អក់ទេ?

អឿង ៖ ល្អក់ ។

ដានី ៖ ងូតរាល់ថ្ងៃឬក៏អត់ទេ?

អឿង ៖ មិនបានងូតមិនបានអីទេ ម៉ាអាទិត្យមិនទាន់បានងូតម្ដងផង ។

ដានី ៖ ងូតទឹកម៉ាអាទិត្យបានងូតម្ដង?

អឿង ៖ កាលលើកទំនប់ម៉ាអាទិត្យមិនទានបានងូតម្ដងផង ទឹកភក់ៗចេះតែផឹកកទៅ ។

ដានី ៖ កាលហ្នឹងមីងខ្លាចគេហ្នង?

អឿង ៖ មិនខ្លាចម៉េចលោកគ្រូអើយ ខ្លាចឡើងរួញ ខ្លាចគេយកទៅវៃចោល ។

ដានី ៖ ដែលឃើញគេយកទៅវ៉ៃចោលផ្ទាល់ភ្នែកទេ?

អឿន ៖ អត់ដែលឃើញទេ ឃើញតែគេចងយកទៅ ។

ដានី ៖ អ្ហូ!ពីណាអ្នកចងយកទៅ?

អឿន ៖ គេប្រធានគេហ្នឹងដូចថាយើងធ្វើការមិនល្អទៅ គេយកទៅវ៉ៃចោល ។

ដានី ៖ ប្រធានណាទៅ?

អឿន ៖ មិនដឹងប្រធានណាទេ ខ្ញុំមិនសូវស្គាល់ឈ្មោះគេផង ខ្លាចគេមិនដែលហានមើលមុខគេចំទេ ។

ដានី ៖ ខ្លាចគេអត់ដែលហានមើលមុខគេចំទេ?

អឿន ៖ ចា៎!អត់ហានទេ ។

ដានី ៖ ប្រធានក្តាប់រួមគេឈ្មោះអី?

អឿន ៖ អត់ដឹង អត់ស្គាល់ទេច្រើនពេកមិនដឹងអ្នកណាប្រធានក្តាប់រួម មិនដឹងអ្នកណាប្រធាន ។

ដានី ៖ ចុះឃើញចាប់ចងចាប់អីហ្នឹងអ្នកណាអ្នកចាប់?

អឿន ៖ ឃើញតែគេកំពុងតែលើកវែកដីៗ គេចងយកទៅក៏មិនហានមើលទេខ្លាចគេ ។

ដានី ៖ អត់ហានមើលខ្លាចគេ?

អឿន ៖ ចា៎!

ដានី ៖ ចុះកាលហ្នឹងអត់មានខុសសីលធម៌មានអីទេ?

អឿន ៖ កាលហ្នឹងដូចមិនមានខុសសីលធម៌ទេ ។

ដានី ៖ កាលហ្នឹងអ្នកលើកទំនប់ហ្នឹង ភាគច្រើនស្រីៗឬក៏មានប្រុសៗច្រើនដែរ?

អឿន ៖ ប្រុសក៏ច្រើន ស្រីក៏ច្រើនស្មើគ្នាលោកគ្រូ ។

ដានី ៖ ចុះមីងកាលពីសម័យហ្នឹងមានដែលឃើញគេចាប់ គេសម្លាប់ឬមានគុកអីនៅក្បែរត្រពាំងថ្មហ្នឹងអត់?

អឿន ៖ ទេ!ដូចមិនឃើញមានគុកមានអីទេ ខ្ញុំអាល័យតែលើកទំនប់ខ្ញុំមិនបានឃើញអីទេ មិនដែលបានដើរទេ លើកតែទំនប់ក៏អស់កម្លាំងទៅ ទៅដល់ក្នុងមុងទៅនាំគ្នាដេកទៅ មិនដឹងថាគុកគេត្រង់ណាត្រង់ណីទេ អត់ស្គាល់ទេ មិនដែលបានស្គាល់ទេ គ្នាវាច្រើន ។

ដានី ៖ ចុះមីងកាលហ្នឹងមីងលើកទំនប់នៅហ្នឹងបានរយៈពេលប៉ុន្មានដែរ?

អឿន ៖ បាន៣-៤ខែ ។

ដានី ៖ បានតែ៣-៤ខែទេ?

អឿង ៖ ចា៎!

ដានី ៖ ៣-៤ខែកាលហ្នឹងពេលមីងទៅហ្នឹងលើករូចដែរឬអត់?

អឿង ៖ លើករូច លើកឡើងរួចបានចប់សព្វគ្រប់ ។

ដានី ៖ បើតាមមីងចាំ កាលលើកទំនប់ហ្នឹងចាប់ពីកន្លែងណាទៅកន្លែងណាទៅ?

អឿង ៖ អ្ហូ!ភ្លេចអស់ហើយ បើគេវាស់មួយចេះទៅៗ បើយូរឆ្នាំហើយភ្លេចអស់ហើយ មិនសូវចាំទេ គេវាស់ឲ្យគិតតែពីលើក ។

ដានី ៖ គេវាស់ឲ្យលើកគិតតែពីលើក អត់ដឹងថាគិតចាប់ពីកន្លែងណាទៅកន្លែងណាទេ?

អឿង ៖ ចា៎!មិនដឹងថាភូមិណាភូមិណាទេ គេវាស់ឲ្យលើក ចេះតែពីលើកៗទៅ ។

ដានី ៖ មីងចាំទេថាកាលហ្នឹងបាតទំនប់អី ប្រវែងបណ្ដោយប៉ុន្មានដែរ?

អឿង ៖ ឮគេថា១៥ម៉ែត្រ ។

ដានី ៖ បាតទំនប់ប្រវែង១៥ម៉ែត្រ ចុះខ្នងទំនប់?

អឿង ៖ ខ្នងធំណាស់ មិនដឹងជាប៉ុន្មានម៉ែត្រទេ ជៀសឡាន២ចេះដុត ។

ដានី ៖ ចុះមានស្ពានទេ?

អឿង ៖ មានស្ពានធំប៉ុនណាណី ។

ដានី ៖ ស្ពានប៉ុន្មានទៅ?

អឿង ៖ អ្ហូ!ច្រើនណាស់លោកគ្រូមិនបានជារាប់អស់ទេ ។

ដានី ៖ ហើយមីងបានដើរនៅលើខ្នងទំនប់ហ្នឹងដែរ?

អឿង ៖ ដើរ ។

ដានី ៖ ដែលបានដើរពីចុងដល់ដើមដែរ?

អឿង ៖ អ្ហូ!មិនដែលបានដើរពីចុងដល់ដើមទេ មិនដែនបានដើរទេគ្រាន់តែរែកឡើងលើកទំនប់រែកចាក់ៗចុះមោវិញ ។

ដានី ៖ ខ្ពស់ទេទំនប់ហ្នឹង?

អឿង ៖ ខ្ពស់គ្រាន់ដែរ ។

ដានី ៖ កម្ពស់ប៉ុន្មានដែរបើតាមមីងគិត?

អឿង ៖ កម្ពស់ជិត៣ម៉ែត្រដែរ ។

ដានី ៖ អញ្ចឹងដល់ពេលលើកទំនប់ហើយគេបញ្ជូនមីងម៉ោវិញឬម៉េច ពេលហ្នឹងតែលើកហើយគេឲ្យម៉ោវិញទាំងអស់គ្នា?

អឿន ៖ ចា៎!គេឲ្យម៉ោវិញទាំងអស់គ្នា ខ្ញុំម៉ោដើមគរ៣ដើម ។

ដានី ៖ ម៉ោនៅដើមគរ៣ដើមវិញ?

អឿន ៖ ចា៎!ម៉ោនៅដើមគរ៣ដើមវិញ ធ្វើស្រែ ដកសំណាប ។

ដានី ៖ ម៉ោដល់ដើមគរ៣ដើមធ្វើអីទៅ?

អឿន ៖ ធ្វើស្រែ ស្ទូង ដកសំណាប ធ្វើស្រែប្រាំងស្រែវស្សា សម្រាកតែមួយថ្ងៃទេមួយខែ ៣០ថ្ងៃ មិនដែលមានថ្ងៃអាទិត្យថ្ងៃព្រហស្បត្តិ៍ទេ ដកសំណាបយប់ម៉ោង១០បាន សម្រាក ហើយពេលយើងដកសំណាបហើយទៅស្ទូងម៉ោង៧ តែម៉ោង៣គេដាស់ឲ្យ ក្រោកហើយ ។

ដានី ៖ អញ្ចឹងម៉ោកន្លែងគរ៣ដើមហ្នឹងយើងម៉ោធ្វើស្រែវិញ?

អឿន ៖ ចា៎!ដកស្ទូងស្រែបាំងផង ស្រែវស្សាផង ។

ដានី ៖ ប៉ុន្តែអត់យ៉ាប់ដូចនៅត្រពាំងថ្មទេ?

អឿន ៖ យ៉ាប់ដែរ ប៉ុនចេះតែស៊ូ ប៉ុនវាគ្រាន់ជាងរែកដី វាមិនបានសូវធ្ងន់ ។

ដានី ៖ គ្រាន់ជាងរែកដី?

អឿន ៖ ចា៎!ស្ទូងគ្មានថ្ងៃសម្រាកទេ ចេះតែដកសំណាបគ្មានសម្រាកទេ ។

ដានី ៖ ចុះកាលហ្នឹងមានផ្លាស់ប្តូរប្រធានអត់ អ្នកប្រធានៗគេមានផ្លាស់ប្តូរពីណាៗទេ?

អឿន ៖ ទេ!មិនបានផ្លាស់ទេ វានៅតែដដែល អានេះផ្លាស់ពេលនិរតីគេចូលម៉ោ ។

ដានី ៖ ពេលនិរតីចូលម៉ោមីងនៅកន្លែងណា?

អឿន ៖ ខ្ញុំនៅដើមគរ៣ដើមហ្នឹង ។

ដានី ៖ នៅត្រពាំងថ្មអត់ទាន់មានពួកនិរតីទេ?

អឿន ៖ ទេមិនទាន់មានទេ ខ្ញុំមិនសូវស្គាល់ទេ អាណាប្រធានៗគេទេ ។

ដានី ៖ អញ្ចឹងពួកនិរតីចូលម៉ោពេលមីងចេញពីទំនប់ត្រពាំងថ្មហើយៗ?

អឿន ៖ ចា៎!

ដានី ៖ អញ្ចឹងកាលម៉ោកន្លែងគរ៣ដើមហ្នឹង ពួកនិរតីម៉ោមីងមានស្គាល់ឈ្មោះគេទេ ឈ្មោះអីខ្លះទៅ?

អឿន ៖ មិនដឹងឈ្មោះអីទេ មិនដឹងឈ្មោះអីខ្លះទេពួកវា ឈ្មោះវាមីកំភ្លួងមួយ ឈ្មោះមីចាន់មួយ ។

ដានី ៖ ឈ្មោះភ្លួងមួយ ឈ្មោះចាន់មួយ?

អឿង ៖ ចា៎! ចាំបាន២ឈ្មោះហ្នឹង ច្រើនណាស់ប៉ុនវាមិនសូវចាំបានទេ ឲ្យយើងដកសំណាបមួយថ្ងៃ៥ស្ទឹក ។

ដានី ៖ កាលហ្នឹងដករួចប្អត់៥ស្ទឹក?

អឿង ៖ រួចលោកគ្រូរួច ។

ដានី ៖ ចាន់ ហើយភ្នួងហ្នឹងគេប្រើយើងឲ្យដក?

អឿង ៖ ចា៎! គេប្រើយើងមួយថ្ងៃដកឲ្យបាន៥ស្ទឹក ។

ដានី ៖ ចុះ ចាន់ ហើយភ្នួងហ្នឹងដកខ្លួនឯងដែរប្អត់?

អឿង ៖ ហ៎! គេឈរតែបញ្ជាគេទេ ។

ដានី ៖ គេឈរតែបញ្ជាទេ គេអត់ដែលដកខ្លួនឯងទេ?

អឿង ៖ ចា៎!

ដានី ៖ ចុះគេដែលហូបចុកអីជាមួយយើងដែរប្អត់?

អឿង ៖ ទេ! គេមិនដែលហូបចុកអីជាមួយយើងទេ បង១គេហូបសុទ្ធតែបាយឆ្ងាញ់ ស្ងោរមាន់ស្ងោរអី ។

ដានី ៖ ចុះយើងហូបអី?

អឿង ៖ ថ្ងៃណាក៏អំបិលលីងទៅ ថ្ងៃណាក៏ស្ងោរផ្អីដាក់ប្រហុក ថ្ងៃណាក៏ដាក់អំបិលត្រីសុទ្ធសាធយកមកឲ្យ ។

ដានី ៖ តែប្រធានគេ គេអត់ហូបជាមួយទេ?

អឿង ៖ ទេ! លោកគ្រូអើយមិនដែលមានបិចចេងណា ដាក់តែអំបិល ។

ដានី ៖ ដាក់តែអំបិលទេ?

អឿង ៖ ចា៎! ស្ងោរផ្អីគេដាក់តែអំបិលតិចទេ ទឹកភាវ១ បែកគ្នាម្នាក់មា៉វែក១ ។

ដានី ៖ បាទ! ចុះកាលហ្នឹងដែលពូឈ្មោះយាយថែមទេ?

អឿង ៖ ពូ ប៉ុនដែលឃើញតែគាត់ជិះឡាន គាត់មិនដែលបានប្រជុំជាមួយខ្ញុំទេ ។

ដានី ៖ មីងអត់ដែលប្រជុំជាមួយគាត់ទេ?

អឿង ៖ ទេ! ខ្ញុំជួបគាត់មួយដងបើកមហាសន្និបាតនៅស្រុកកើតនោះ ។

ដានី ៖ នៅណា?

អឿង ៖ នៅភូមិឱម៉ាល់ផ្លូវកាត់នោះ ដែលខ្ញុំលើកទំនប់គេថាសែងកាត់ស្ទឹង គាត់មកសម្ភាសន៍មួយដង ។

ដានី ៖ គាត់ទៅបើកសន្និបាតនៅហ្នឹងមួយដងៗ?

អឿង ៖ ចា៎! ទៅមួយដងគត់ ដែលពួកខ្ញុំលើករូបគាត់ទៅមួយដង ។

ដានី ៖ គាត់ទៅបើកសន្និបាតគាត់និយាយថាម៉េចខ្លះ?

អឿង ៖ ឲ្យតែយើងបងប្អូនខំលើកទំនប់ ជីកប្រឡាយ ឲ្យយើងប្ដេជ្ញាលើកឲ្យបានឆាប់រួច ។

ដានី ៖ ចុះកាលហ្នឹងយាយចែម រូបរាងគាត់យ៉ាងម៉េចទៅ?

អឿង ៖ រូបគាត់ស សទាបស្ដើង សំដីគាត់និយាយមួយៗ ។

ដានី ៖ ចំនាស់ណាកាលហ្នឹង កាលមីងឃើញ?

អឿង ៖ ចាស់ហើយ អាយុប្រហែល៥០-៦០ហើយ ។

ដានី ៖ គាត់ជិះឡានយ៉ាងម៉េចឡានគាត់?

អឿង ៖ ឡានពណ៌សៗ ។

ដានី ៖ គាត់ចិះឡានតែមាក់ឯង?

អឿង ៖ ទេ! មានគ្នាគេ២-៣នាក់ ។

ដានី ៖ កាលហ្នឹងគាត់ធ្វើអី?

អឿង ៖ មិនដឹងធ្វើអីទេ កាលហ្នឹងខ្ញុំមិនស្គាល់ ពួកគេថាគាត់ប្រធានៗ ។

ដានី ៖ ប្រធានអីទេ?

អឿង ៖ មិនដឹងប្រធានស្អីខ្ញុំមិនដឹង ពួកគេថាប្រធានៗយាយចែម ក៏ថាគេទៅ ។

ដានី ៖ យាយចែមគាត់ធ្វើប្រធាននៅណាទៅ?

អឿង ៖ នៅស្វាយសិរីសោភ័ណ នៅខេត្តបន្ទាយមានជ័យ ។

ដានី ៖ ផ្ទះគាត់នៅនោះ?

អឿង ៖ ទេ! នៅនោះដឹងឯង ខ្ញុំពួកតែគេថាអញ្ចឹង គាត់នៅខេត្តបន្ទាយមានជ័យហ្នឹង នៅសម័យ ៣ឆ្នាំហ្នឹង ប៉ុនមិនដែលបានឃើញផ្ទះគាត់ទេ ។

ដានី ៖ កាលហ្នឹងពេលគាត់ទៅបើកសន្និបាតហ្នឹង កាលហ្នឹងពេលមីងនៅគរ៣ដើមឬនៅណា?

អឿង ៖ នៅកើតខ្ញុំលើកទំនប់ ។

ដានី ៖ ក្រែងចេញពីត្រពាំងថ្មម៉ោ មីងនៅកន្លែងគរ៣ដើម?

អឿង ៖ ចា៎! ខ្ញុំលើកទំនប់នេះរួច បានទៅនោះ ។

ដានី ៖ ទៅណាទៀត?

អឿង ៖ ទៅត្រពាំងថ្ម ។

ដានី ៖ កាលហ្នឹងយាយទៅសម្ភោធហ្នឹង ពីមុនទៅត្រពាំងថ្មទៀត?

អឿង ៖ ចាំ!មុនទៅត្រពាំងថ្មទៀត ។

ដានី ៖ អញ្ចឹងក្រែងយាយ ចែម ក្រែងពួកនិរតី?

អឿង ៖ ពួកនិរតី ។

ដានី ៖ អញ្ចឹងក្រែងយាយចែម ម៉ោក្រោយលើកត្រពាំងថ្មហើយ?

អឿង ៖ ចាំ!កាលមុនអាជិតចូលនេះក៏គាត់ចូលបណ្ដោយ ។

ដានី ៖ ជិតចូលម៉េច?

អឿង ៖ ជិតចូលដែលយើងថា ចេញទៅត្រពាំងថ្មៗហ្នឹងគេថាយាយចែមម៉ោៗ ខ្ញុំក៏មិនសូវស្គាល់ដងព្រុតែគេថា ។

ដានី ៖ ពេលជិតយួនចូលឬក៏យ៉ាងម៉េច ពេលយាយចែមទៅកំពតហ្នឹង?

អឿង ៖ អាជិតយួនចូល ។

ដានី ៖ អញ្ចឹងដល់ពេលយួនចូលហើយមីងទៅណាទៀត?

អឿង ៖ ជិតយួនចូលហើយក៏ម៉ោផ្ទះគេឲ្យម៉ោផ្ទះវិញ ។

ដានី ៖ គេឲ្យម៉ោផ្ទះវិញ?

អឿង ៖ ចាំ!

ដានី ៖ ចុះមីងរៀបការឆ្នាំណា?

អឿង ៖ មិនដឹងឆ្នាំណាទេ ។

ដានី ៖ អញ្ចឹងមីងខ្ញុំដូចជាអសស់សំនួរអីត្រូវសួរនាំមីងទៀតហើយ មីងមានអីត្រូវចង់បន្ថែមនូវអាអ៊ីដែលខ្ញុំអត់ទាន់បានសួរទៀតទេ?

អឿង ៖ ខ្ញុំអស់ហើយ ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណមីងច្រើន ។

អឿង ៖ ចាំ!

ចប់